ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# សាកលវិទ្យាល័យ អង្គរខេមរា

# ANGKOR KHEMARA UNIVERSITY

មហាវិទ្យាល័យ

College

សិល្បៈ មនុស្សសាស្ត្រ និងភាសា

Arts, Humanities and Languages

ឯកទេស៖ អក្សរសាស្ត្រខ្មែរ

Specialty: Khmer Literature

## មុខវិជ្ជា៖ អក្សរសិល្ប៍ក្រោយអង្គរ-

## (ឧដុង្គ លង្វែក បារាំង)

## <u>ប្រធានបទ</u>

## *“ចរិយាសាស្ត្រសង្គមខ្មែរតាមរយៈរឿងមាយើង”*


បង្រៀននិងណែនាំដោយ៖ **បណ្ឌិត ឃិន យ៉ង់**

រៀបរៀងដោយនិស្សិតថ្នាក់ ៖ បរិញ្ញាបត្រ

Witten by Undergraduate Students

**ឌី ជីវ័ន្ត** (ប្រុស)

និស្សិតអក្សរសាស្ត្រខ្មែរ ជំនាន់ទី១៤ វគ្គទី០១ ឆមាសទី០២ ឆ្នាំទី០៣ សាខាពោធិ៍សាត់


ព.ស២៥៦៧ ឆ្នាំសិក្សា៖២០២៣-២០២៤ គ.ស ២០២៤

# ឧទ្ទិសកថា

ខ្ញុំសូមឧទ្ទិសស្នាដៃនេះជូនចំពោះ៖

- វិញ្ញាណក្ខន្ធបុព្វបុរសខ្មែរគ្រប់រូបដែលបានធ្វើពលិកម្មគ្រប់បែបយ៉ាងដើម្បីការពារជាតិមាតុភូមិ។
- វិញ្ញាណក្ខន្ធកវី បណ្ឌិត អ្នកនិពន្ធ អ្នកប្រាជ្ញខ្មែរគ្រប់ជំនាន់។ ដែលបានខិតខំថែរក្សាអក្សរសាស្ត្រជាតិឱ្យរីកចម្រើនគង់វង្សរហូតមកដល់សព្វថ្ងៃ។
- វិញ្ញាណក្ខន្ធសម្ដេចព្រះសង្ឃរាជ ជួន ណាត ដែលព្រះអង្គបាន បន្សល់ស្នាដៃដ៏វិសេសវិសាលសម្រាប់កូនខ្មែរគ្រប់ជំនាន់នោះគឺ សៀវភៅវចនានុក្រមខ្មែរ។
- វិញ្ញាណក្ខន្ធនៃបុព្វការីជនរបស់ខ្ញុំទាំងអស់។

សូមជួយទ្រទ្រង់វិស័យអក្សរសាស្ត្រជាតិឱ្យកាន់តែរីកចម្រើនជានិច្ចនិរន្តរ៍។

# សេចក្តីថ្លែងអំណរអរគុណ

ទន្ទឹមនឹងការកកើតនូវស្នាដៃឡើងបានជាលទ្ធផលនេះខ្ញុំបាទសូមសម្តែងនូវអំណាគុណជាអនេកប្រការចំពោះ ៖

លោកឪពុក អ្នកម្តាយនៃខ្ញុំទាំងឡាយជាបុព្វាចារ្យនឹងជាព្រះអរហន្តដ៏ប្រសើររបស់ខ្ញុំបាទដែលលោកបានផ្តល់នៅកំណើត ហើយចិញ្ចឹមបីបាច់ថែរក្សាដោយព្រហ្មវិហារធម៌។ ជានិច្ចកាលលោកតែងតែណែនាំ ចង់ឲ្យក្លាយជាគ្រាប់ពូជដ៏មានតម្លៃមួយ។

លោកគ្រូ អ្នកគ្រូទាំងអស់តាំងពីថ្នាក់បឋមសិក្សារហូតមកដែលអស់លោកបានបង្ហាត់បង្រៀនឲ្យខ្ញុំបាទនៅទ្រព្យសម្បត្តិដែលមិនអាចកាត់ថ្លៃបានពោលគឺចំណេះវិជ្ជា ព្រមទាំងសីលធម៌ សុជីវធម៌ក្នុងសង្គមធ្វើឲ្យ ក្លាយជាធនធានដ៏មានតម្លៃមួយសម្រាប់សង្គមជាតិ។

បណ្ឌិត **នូ ចាន់សុភី** សាកលវិទ្យាធិការ នៃសាកលវិទ្យាល័យអង្គរខេមរា និងគណៈគ្រប់គ្រងនៃសាកលវិទ្យាល័យអង្គរខេមរាទាំងអស់ធ្វើឲ្យខ្ញុំបានទទួលបានចំណេះដឹងដ៏មានតម្លៃសម្រាប់ជួយខ្លួនឯង គ្រួសារ និងសង្គមជាតិបានមួយចំណែក។

សាស្ត្រាចារ្យក្នុងឯកទេសអក្សរសាស្ត្រខ្មែរនៃសាកលវិទ្យាល័យអង្គរខេមរាទាំងអស់ដែលបានខិតខំប្រិតប្រៀនតម្រែតម្រង់នៅមុខវិជ្ជាទាំងឡាយក្នុងជំនាញអក្សរសាស្ត្រខ្មែរញុំាងឲ្យខ្ញុំបាទទទួលនូវចំណេះដឹងយ៉ាងស្រួចស្រាល់លើជំនាញរបស់ខ្ញុំ។ ជាពិសេសសូមអរគុណជាអនេក ចំពោះសាស្ត្រាចារ្យបណ្ឌិត **ឃិន យ៉ាំ** ដែលបង្រៀនលើមុខវិជ្ជាអក្សរសិល្ប៍សម័យក្រោយអង្គរ-(ឧដុង្គ លង្វែក បារាំង)ដែលបានណែនាំកែតម្រូវលើការស្រាវជ្រាវមួយនេះ។

# មាតិកា

**I ជំពូកទី១៖ សេចក្តីផ្តើម** ........................................................ ទំព័រទី១

១.១ ប្រវត្តិបញ្ហា

១.២ ចំណោទបញ្ហា

១.៣ គោលបំណងនាំការស្រាវជ្រាវ

១.៤ ដែនកំណត់

១.៥ វិធីសាស្ត្រស្រាវជ្រាវ

១.៦ សារប្រយោជន៍នៃការស្រាវជ្រាវ

១.៧ រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

**II ជំពូកទី២៖ អំពីរឿងមាយើង** ........................................................ ទំព័រទី៣

២.២ ប្រវត្តិ

២.៣ អ្នកនិពន្ធ

**III ជំពូកទី៣៖ ការវិភាគអត្ថន័យ អត្ថរូប អត្ថរស** ........................................ ទំព័រទី៤

**៣.១ វិភាគអត្ថន័យ**

៣.១.១ សង្ខេបរឿង

៣.១.២ ប្រធានរឿង

៣.១.៣ មូលបញ្ហារឿង

៣.១.៤ វិភាគតួអង្គ

៣.១.៥ វិភាគបញ្ហាផ្សេងៗ

**៣.២ វិភាគអត្ថរូប**

៣.២.១ វិភាគពាក្យពេចន៍

៣.២.២ វិភាគជើងកាព្យ

៣.២.៣ រូបារម្មណ៍វិធី

**៣.៣ វិភាគអត្ថរស**

៣.៣.១ តថរស

៣.៣.២ វីររស

៣.៣.៣ សង្គមរស

៣.៣.៤ វិភាគកុសលរស

**IV ជំពូកទី៤៖ លក្ខណៈវិជ្ជមាន អវិជ្ជមាន** (ឥទ្ធិពល តម្លៃសង្គម ការអប់រំ...) ........................ ទំព័រទី១១

៤.១ លក្ខណៈវិជ្ជមាន

៤.២ លក្ខណៈអវិជ្ជមាន

**V ជំពូកទី៥៖ សន្និដ្ឋាន** ........................................................................................ ទំព័រទី១២

ឯកសារពិគ្រោះ

# I ជំពូកទី១៖ សេចក្ដីផ្ដើម

## ១.១ ប្រវត្តិបញ្ហា

ស្នាដៃអក្សរសិល្ប៍ខ្មែរបានផ្លាស់ប្ដូរទៅលើអត្ថន័យ អត្ថរូប ស្របទៅតាមសម័យកាលនៃប្រវត្តិសាស្ត្រ រហូតដល់មានការបែងចែកអក្សរសិល្ប៍ជាបីស័យកាលគឺ អក្សរសិល្ប៍សម័យបុរាណ អក្សរសិល្ប៍សម័យកណ្ដាល និងអក្សរសិល្ប៍សម័យទំនើប ព្រមទាំងចែកប្រភេទអក្សរសិល្ប៍ជាបីប្រភេទគឺ អក្សរសិល្ប៍បែបសាស្ត្រល្បែង អក្សរសិល្ប៍បុរាណ និងអក្សរសិល្ប៍ទំនើប។

ដោយផ្អែកលើទ្រឹស្ដីនៃការសិក្សាលើមុខវិជ្ជាអក្សរសិល្ប៍ខ្មែរ បានកំណត់ថារាល់ស្នាដៃ ដែលតាក់តែងឡើងដោយពុំបញ្ជាក់ពីកាលបរិច្ឆេទ និងអក្នទិពន្ធ ដោយនិយមនិទានតៗគ្នា ពីមាត់ មួយទៅមាត់មួយ ពីតំបន់មួយទៅតំបន់មួយនោះគឺជាអក្សរសិល្ប៍ប្រភេទអក្សរសិល្ប៍បុរាណបែបសាស្ត្រាល្បែង។ ក្រោយពីបានសិក្សា ស្នាដៃរួចមក យើងឃើញថា រឿងមាយើង គឺជាអក្សរសិល្ប៍បែបសាស្ត្រាល្បែងដែលមានអត្ថន័យ អត្ថរូប និងអត្ថរស ប្រកបដោយលក្ខណៈល្អវិសេសវិសាល។ អ្នកនិពន្ធបាន តាក់តែងជាកាព្យដែលទទួលបានការចាប់ អារម្មណ៍ ពេញចិត្តជាខ្លាំងពីមហាជន នៅប្រទេសកម្ពុជាយើង។ ទៀតសោតស្នាដៃនេះបានបង្កប់នូវតម្លៃជាច្រើន ដែលរាប់តាំងពីចរិយាស្រ្ដី របបគ្រប់គ្រង ទំនៀមទម្លាប់ ជីវភាពរសនៅ ចរិយាសាស្ត្ររបស់សង្គម ស្ថានភាព គ្រួសារជាដើម។ តម្លៃទាំងនេះបានផ្ទុកទៅដោយឧត្ដមគតិ ដំបូន្មាន គំនិតល្អៗ។ ដូចនេះហើយទើបខ្ញុំបាទ សម្រេចយកស្នាដៃ រឿងមាយើងក្នុងអក្សរសិល្ប៍ខេមរនិយម ប្រភេទអក្សរសិល្ប៍បែបសាស្ត្រល្បែង មកសិក្សា ប្រធានបទថា "ចរិយាសាស្ត្រក្នុងសង្គមខ្មែរតាមរយៈរឿងមាយើង" ។

## ១.២ ចំណោទបញ្ហា

រឿងមាយើង គឺជាប្រភេទអក្សរសិល្ប៍បែបសាស្ត្រល្បែង ដែលការតាក់តែងឡើងប្រកបទៅដោយសិល្បវិធីយ៉ាងល្អឯក។ រឿងមាយើងបានបង្ហាញពីជីវភាពរសនៅប្រចាំថ្ងៃរបស់ប្រជាជនខ្មែរយើង និងរបបគ្រប់គ្រង ដោយស្ដេច។ដូចនេះហើយការយករឿងមាយើងមកសិក្សាដើម្បីឱ្យឃើញពីចរិយាសាស្ត្រក្នុងសង្គមខ្មែរ៖

-តើស្ត្រីខ្មែរនាសម័យនោះមានចរិយាសាស្ត្របែបណា?

-តើចរិតរបស់បុរសមានសម័យនៅមានចរិតបែបណា?

-តើរឿងមាយើងបង្ហាញពីចរិយាសាស្ត្ររបស់មនុស្សបែបណា?

## ១.៣ គោលបំណងនៃការស្រាវជ្រាវ

ការជ្រើសរើសយកប្រធានបទ "ចរិយាសាស្ត្រក្នុងសង្គមខ្មែរតាមរយៈរឿងមាយើង" មកធ្វើការសិក្សាស្រាវជ្រាវនេះគឺ ក្នុងគោលបំណង៖

- យល់ដឹងពីចរិតក្នុងសង្គមខ្មែរមានសម័យនោះ
- ដើម្បីបន្សល់ទុកជាមេរៀនឬ ជាឯកសារនៃការវិភាគរឿងមាយើង សម្រាប់អ្នកសិក្សាជំនាន់ក្រោយ
- លើកកម្ពស់ដល់ការសិក្សាស្រាវជ្រាវ លើវិស័យអក្សរសិល្ប៍ខ្មែរឱ្យកាន់តែរីកចម្រើន
- ចូលរួមលើកតម្លៃនៃស្នាដៃតែងនិពន្ធ របស់អ្នកនិពន្ធខ្មែរជំនាន់មុនៗ។

## ១.៤ ដែនកំណត់

ក្នុងការសិក្សានេះ ដោយផ្អែកទៅលើអក្សរសិល្ប៍បែបសាស្ត្រល្បែងខ្មែរយើង សម្រាប់លើយកមកធ្វើការវិភាគឱ្យឃើញនូវចរិយាសាស្ត្រក្នុងសង្គមខ្មែរ ដែលកើតមានឡើងក្នុងរឿងមាយើងមកធ្វើការចោទនិងស្រាយ។

## ១.៦ សារប្រយោជន៍នៃការស្រាវជ្រាវ

ចំពោះការសិក្សារឿងមាយើង គឺជាការសិក្សាដើម្បីពង្រឹងនូវចំណេះដឹងបន្ថែមទៅលើស្នាដៃអក្សរសិល្ប៍ប្រជាប្រិយនិងរក្សាស្នាដៃដែលជាកេរដំណែលរបស់ខ្មែរយើង បានបន្សល់ទុកតាំងពីបុរាណ ព្រមទាំងបានបន្សល់ទុកស្នាដៃឱ្យអ្នកសិក្សាជំនាន់ក្រោយបានយល់ បានដឹង និងបានស្គាល់ ព្រមទាំងទុកឱ្យអ្នកសិក្សាជំនាន់ក្រោយទុកជាឯកសារប្រើប្រាស់ទៅតាមតម្រូវការរបស់។ ក្នុងការសិក្សាស្រាវជ្រាវនេះ ខ្ញុំបាទសង្ឃឹមថានៅពេលដែលស្រាវជ្រាវ បានបញ្ចប់ដោយជោគជ័យ កិច្ចការស្រាវជ្រាវនេះនឹងផ្តល់ជាសារៈប្រយោជន៍ជាច្រើនចំពោះសង្គមខ្មែរ ដូចជា៖

- ផ្តល់ជាចំណេះដល់អ្នកអានពីបញ្ញត្តិ ទ្រឹស្តីផ្សេងៗ ដែលទាក់ទងនឹងចរិយាសាស្ត្រក្នុងសង្គមខ្មែររបស់អក្សរសិល្ប៍បែបសាស្ត្រល្បែង
- បានជាចំណេះដឹងសំខាន់ៗ ពីការសិក្សាវិភាគបញ្ហាក្នុងស្នាដៃ
- រួមចំណែកក្នុងការកសាងធនធានឯសារ ដែលទាក់ទងទៅនឹងអក្សរសិល្ប៍បែបសាស្ត្រល្បែង
- ចូលរួមការពារនូវអត្តសញ្ញាណជាតិ ដោយបានលើស្ទួយលើវិស័យអក្សរសិល្ប៍ដែលបានផ្តល់ជាឧត្តមគតិក្នុងសង្គមរបស់ខ្មែរ ជាពិសេសនោះទុកជាមូលដ្ឋាន សម្រាប់អ្នកសិក្សាជំនាន់ក្រោយឱ្យយល់ច្បាស់ថា ជាតិខ្មែរមានអក្សរសិល្ប៍ដែលបង្កប់នូវគំនិតល្អៗសម្រាប់ផ្តល់ជាគតិអប់រំដល់មនុស្សជំនាន់ក្រោយទៀតផង។

## ១.៧ រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

ការសិក្សានេះយើងធ្វើការរៀបចំរចនាសម្ព័ន្ធដូចខាងក្រោម៖

- ជំពូកទី១៖ សេចក្ដីផ្ដើម ដែលមានប្រវត្តិបញ្ហា ចំណោទបញ្ហា គោលបំណងនៃការស្រាវជ្រាវ ដែនកំណត់ វិធីសាស្ត្រស្រាវជ្រាវ សារប្រយោជន៍នៃការស្រាវជ្រាវ រចនាសម្ព័ន្ធនៃការស្រាវជ្រាវ។
- ជំពូកទី២៖ អំពីរឿងមាយើង ប្រវត្តិ អ្នកនិពន្ធ។
- ជំពូកទី៣៖ ការវិភាគអត្ថន័យ(សង្ខេបរឿង ប្រធានរឿង មូលបញ្ហារឿង វិភាគតួអង្គ វិភាគបញ្ហាផ្សេងៗ) វិភាគអត្ថរូប(វិភាគពាក្យពេចន៍ វិភាគជើងកាព្យ) វិភាគអត្ថរស(វិភាគ អច្ឆរិយរស វិភាគកុសលរស វិភាគទារុណរស វិភាគហាសរស)។
- ជំពូកទី៤៖ លក្ខណៈវិជ្ជមាន អវិជ្ជមាន (ឥទ្ធិពល តម្លៃសង្គម ការអប់រំ...)។
- ជំពូកទី៥៖ សន្និដ្ឋាន និងឯកសារពិគ្រោះ។

## II ជំពូកទី២៖ អំពីរឿងមាយើង

### ២.២ ប្រវត្តិ

រឿងមាយើង គឺជាអក្សរសិល្ប៍បែបសាស្ត្រល្បែង ដែលមានការនិទានពីមាត់មួយទៅមាត់មួយពីតំបន់មួយទៅ តំបន់មួយដែលរឿមរាប់ពីជីវភាពរស់នៅរបស់ប្រជារាស្ត្រ ព្រមទាំងបង្ហាញពីការប្រកបរបរបស់ប្រជារាស្ត្រ ខ្មែរយើងដោយការនេសាទ ការលក់ដូរ ការធ្វើជំនួញដោយសំពៅជាដើម។ អ្នកដែលនាំរឿងនេះទៅនិយាយ ផ្សាយក៏ពោលបន្ថែមបន្ថយ ឬបំពេញតាមអធ្យាស្រ័យរបស់ខ្លួនដើម្បីឱ្យពីរោះ ដល់អ្នកស្ដាប់។ ជួនកាលទៀត មានយករឿងរ៉ាវផ្សេងៗមកបញ្ចូលជាមួយបន្ថែមទៀតដើម្បីឱ្យបានអ្នកស្រុកកាន់ តែចូលចិត្តរឿង នេះថែមទៀត។ ហេតុនេះហើយបានជានិទានតៗគ្នាពីមួយទៅមួយបានក្លាយជាការ គោរពស្រឡាញ់ និងជាអក្សរសាស្ត្រសម្រាប់ស្រុកភូមិនីមួយៗក្នុងប្រទេសកម្ពុជាយើង។

### ២.៣ អ្នកនិពន្ធ

គេពុំអាចរកឃើញឈ្មោះអ្នកនិពន្ធទេ តែប្រហែលជាអ្នកប្រាជ្ញខ្មែរដែលចេះអក្សរសាស្ត្រយ៉ាងច្បាស់លាស់ ឬក៏ជាប្រជាជនផ្ទាល់ដែលនិទានឱ្យគ្នាស្ដាប់ក្នុងពេលធ្វើពលកម្មដើម្បីកំដរអប្បុក។

# III ជំពូកទី៣ៈ ការវិភាគអត្ថន័យ អត្ថរូប អត្ថរស

## ៣.១ វិភាគអត្ថន័យ

### ៣.១.១ សង្ខេបរឿង

កាលកន្លងទៅហើយ មានព្រះមហាក្សត្រមួយព្រះអង្គព្រះនាមព្រះហ្មទត្ត សោយរាជ្យក្នុងក្រុងពារាណសី មានព្រះអគ្គមហេសីប្រកបដោយរូបស្រស់សោភា ព្រះទាំងមន្ត្រីយោធា សមណព្រាហ្មណ៍ដោយប្រាជ្ញា។ ទ្រង់គ្រងរាជ្យប្រកបដោយទសពិរាជធម៌ ប្រជានុរាស្ត្រសឹងប្រកបដោយសុខសន្តិភាព ពុំមានកើតកោលាហលក្នុងព្រះនគរឡើយ។ កាលនៅមានមាណពម្នាក់ជាអ្នកកម្សត់ទុគ៌តរស់នៅតែពីរនាក់ប្ដីប្រពន្ធ រីឯនាងប្រពន្ធវិញមានរូបស្រស់សោភា ប៉ុន្តែចិត្តកំណាញ់ ញាតិព្រៀងលានពុំចូលចិត្តឡើយ។

សម័យថ្ងៃមួយមាណពនិងភរិយានាំគ្នាទៅជញ្ជាត់ត្រី ឯកញ្ជើសោត ឆ្នុះស្បិតនាងប្រពន្ធពុំចេះជួយថែរក្សា ពេលដែលប្ដីជញ្ជាត់បានត្រីដាក់ចូល រមែងចេញតាមប្រហោងនោះ។ លុះជញ្ជាត់យូរទៅក៏ជិតដល់សំពៅធំមួយ នាយភេត្រានិងភរិយាក៏មើលពីលើសំពៅមកឃើញកញ្ជើធ្លុះ នាងភរិយាក៏ពោលថានាងជាប្រពន្ធម្ដេចមិនយកអ្វីចុកកុំឱ្យលេច។ ប្ដីនាងក៏ក្រោធ ហើយដេញនាងឱ្យចុះទៅនៅជាមួយមាណពនោះ នាយសំពៅក៏បបួលមាណពនោះដូរប្រពន្ធ។ នាងជាប្រពន្ធថ្មីរបស់មាណពក៏កាន់កញ្ជើដើរទៅរកអ្វីមកចុកកុំឱ្យលេចរួច ដើរជញ្ជាត់តាមប្ដី។ ពេលត្រឡប់មកផ្ទះវិញ មានក៏ចាត់ចែងឱ្យប្ដីយកត្រីជូនញាតិព្រៀងលាន អ្នកជិតខាងសឹងធ្ងល់គ្រប់គ្នាព្រោះថៅមាណព និងប្រពន្ធពុំដែលមានសប្បុរសឡើយ។ លុះពួកគេទៅលេងផ្ទះមាណព ទើបដឹងថាថៅមាណពបានប្រពន្ធថ្មីប្រកបដោយលក្ខិណា។ ថ្ងៃមួយមាណពចូលព្រៃដើម្បីកាប់អុសលុះរែកត្រឡប់មកវិញប្រពន្ធឃើញឈើនោះសុទ្ធតែជាឈើមានតម្លៃ ដូចជា ក្លាំពាក់ ក្រឹស្នាជាដើម ក៏ដេញឱ្យប្ដីកាប់ចងបាច់ទុកឱ្យច្រើន និងអាលជួលរទេះអ្នកជិតខាងឱ្យដឹកគរទុក។ ពេលអ្នកដើរសំពៅរកទិញដើមក្រឹស្នា ក្លាំពាក់ នាងលក់បានទ្រព្យសម្បត្តិជាច្រើន ហើយក៏រៀបចំធ្វើផ្ទះយ៉ាងធំជួលខ្ញុំបម្រើ។ ឯប្ដីនោះក៏បានស្គាល់ថៅដទៃ ស្គាល់ព្រះស្គាល់ពញាជាដើម។ ថ្ងៃមួយនាងស្រដីនឹងប្ដីនាង នាងចង់ឱ្យប្ដីនាងរៀនរត់ឱ្យបានរហ័សដូចចិត្តប៉ងប្រាថ្នា ប្ដីក៏យល់ព្រម។ រត់មួយថ្ងៃដំបូងក៏ប្រាប់ប្រពន្ធថាហត់ស្ទើរដាច់ខ្យល់ស្លាប់ លុះរត់យូរៗទៅលែងហត់។ ប្រពន្ធឃើញប្ដីរបស់ខ្លួនរត់ពុំហត់គ្រប់គ្រាន់បរិបូរណ៍ ក៏នាំទៅជួបនឹងមន្ត្រីដើម្បីសុំផ្ញើប្ដីនៅបម្រើព្រះមហាក្សត្រ។ នាកាលថ្ងៃមួយព្រះមហាក្សត្រទ្រង់ប្រាប់ឱ្យពលសេនារៀបគ្រឿងបណ្ណាការ ព្រោះព្រះអង្គចង់ទៅប្រពាតព្រៃព្រឹក្សា។ ថៅមាណពក៏ប្រាប់ឱ្យប្រពន្ធរៀបចំក្រយាដើម្បីទៅចូលរួមដង្ហែព្រះរាជា។ ឯនាងប្រពន្ធរៀបចំបង្វិចឱ្យប្ដី និងផ្ញិតផ្ញង់ក្រយា សម្រាប់ព្រះមហាក្សត្រ នាងដឹងថាព្រះមហាក្សត្រនឹងឃ្លាតពីមន្ត្រីទាំងឡាយ មានតែមាណពម្នាក់ប៉ុណ្ណោះដែលទៅទាន់។ លុះព្រឹកឡើងពួកពលសេនាក៏រៀបចំដង្ហែព្រះអង្គ ព្រះអង្គទ្រង់បរអេស្សពាហ៍លឿនកន្លង លុះដល់ដើមជ្រៃស្ដេចក៏បញ្ឈប់អស្សពាហ៍។ ទ្រង់ទតពុំឃើញនរណាក្រៅពីមាណព

ទ្រង់ក៏សន្មតនាមថា ថៅមាយើង។ លុះថ្ងៃពេកទ្រង់ឃ្លានក្រយាក៏ប្រាប់ ទៅមាយើងថាមន្ត្រីទាំងឡាយបែកខ្ញែកគ្នាពុំដឹងទៅទីណា មាយើងក៏ទូលទៅថាទូលបង្គំមានបាយ។ ស្តេចសោយបាយ ទឹក ស្លា របស់ដ៏មានឱជារសឆ្ងាញ់ដូចដែលទ្រង់ធ្លាប់សោយរាល់ថ្ងៃ ហើយទ្រង់ក៏សរសើរដល់ប្រពន្ធមាយើងថាជាស្រីប្រកបដោយលក្ខិណាចេះរៀបចំទុកដាក់ឱ្យប្តីមានសព្វគ្រប់ពុំខ្វះឡើយណា។ លុះទ្រង់សោយហើយ ទ្រង់ក៏ផ្ទំលើភ្លៅមាណពហើយមានបន្ទូលថាទ្រង់នឹងនិទានរឿងមួយឱ្យមាណពស្តាប់ ពុំទាន់និទានផងទ្រង់ក៏ផ្ទំលក់ទៅ។ កាលនោះមានទេវតារក្សាដើមជ្រៃបាឮថាស្តេចនឹងនិទានរឿង ក៏បប្ចូលគ្នាមូលមីរលើដើមជ្រៃ លុះយប់ស្តេចនិទ្រាពុំមានបន្ទូលទេវតាក៏ខឹងព្រះបាទព្រហ្មទត្តថាមុសាពុំកាន់ពាក្យសត្យ។ ដូច្នេះយើងនឹងកាច់មែកជ្រៃទម្លាក់សង្កត់ព្រះមហាក្សត្រឱ្យបង់ព្រះជន្មជីវី។ បើពុំបាន ពេលស្តេចទៅដល់បុរីយើងនឹងកាច់ខ្លោងទ្វារសង្កត់ឱ្យក្ស័យ។ បើឆ្លងផុតទៀតពេលស្តេចចូលដល់ព្រះក្រឡាបន្ទំ យើងនឹងក្រឡាជាពស់ទៅខាំ។ មាយើងបានឮពាក្យទេវតាពិភាក្សាគ្នាក៏ដាស់ស្តេចមួយរំពេចទើបទូលស្តេចថាមានទេវតានិត្យនៅរក្សាលើដើមជ្រៃខឹងនឹងព្រះអង្គថានឹងនិទានរឿង ហើយក៏ផ្ទំលក់ស្ងាត់ស្ងៀម។ ស្តេចស្តាប់មាយើងហើយក៏ស្ទុះឡើងលើសេះបំផាយជាមួយមាយើង។ ក្សិណនៅមែកជ្រៃក៏ធាក់ផុតពីក្សត្រថ្លៃ លុះដល់ខ្លោងទ្វារស្តេចប្រាប់ឱ្យមាយើងប្រយ័ត្នជួយវាយគោះសេះឱ្យសេះលោតផ្លោះផុតពីខ្លោងទ្វារដែលទេវតាទម្លាក់មករួចផុតពីក្ស័យ។ លុះចូលមកដល់មណ្ឌល ថៅមាយើងក៏ក្រាបបង្គំលាទៅកាន់គ្រឹះស្ថានរបស់ខ្លួន ព្រះបាទព្រហ្មទត្តមានបន្ទូលផ្តាំថា ចូរទៅចុះហើយវិលត្រឡប់វិលមកចាំដូចថៅឮហោង។ មកដល់ផ្ទះអាត្មា មាយើងក៏ដំណាលប្រាប់ភរិយាអស់សេចក្តី។ លុះមាយើង និងភរិយាហូបបាយហើយមាយើងក៏ទៅអង្គុយចាំ។ កាលនោះឯទេវតាបានប្រែក្រឡាជាពស់ធំប៉ុនដើមត្នោតបើកពពារគួរឱ្យខ្លាចភ្នែកធំក្រដាច រឹងចង្កូមសស្វាច មាយើងក៏លើកខាន់ថ្លាវាត់ដាច់សិរសាឈាមពស់ខ្ទាត់ទៅដល់ថនាព្រះទេពី។ មាយើងគិតថាបើដាស់ក្រឡាបន្ទំយល់ពុំគួរបើយកដៃជូតក៏ពុំជា រួចហើយក៏យកខ្មោចពស់ដាក់ក្រោមក្រឡាបន្ទំហើយហាមាត់លិទ្ធឈាមដែលប្រឡាក់សុដនក្សត្រី។ នាងនាថភ្ញាក់ឡើងក៏ដាស់ព្រះភូមីឱ្យបប្រាប់ថាមាយើងយកជីវ្ហាមកលិទ្ធដោះខ្លួន។ ស្តេចព្រហ្មទត្តស្តាប់ប៉ុណ្ណោះក៏ក្រេវក្រោធពេកក្រៃមិនបានជាគិត ក៏បញ្ជាឱ្យពេជ្ឈឃាតនាំមាយើងទៅប្រហារជីវិតទាំងយប់ ប៉ុន្តែមានការរារាំថពីឆ្មាំយាមទ្វារទិសទាំងបួន ព្រោះថាច្បាប់ប្រចាំព្រះរាជវាំងមិនអាចយកអ្នកទោសទៅប្រហារជីវិតមុនថ្ងៃរះបានទេ ហើយឆ្មាំទ្វារទិសនីមួយៗបានពន្យល់ប្រាប់ពីហេតុផលជាច្រើនដល់ពេជ្ឈឃាត ដើម្បីឱ្យពេជ្ឈឃាតប្រហារជីវិតមាយើង ហើយធ្វើឱ្យព្រះអង្គមានការស្តាយក្រោយ។ និយាយពីស្តេចព្រហ្មទត្ត កាលដែលតើនឡើងនឹករឿងសព្វគ្រប់ឃើញថាថៅមាយើងមានគុណលើព្រះអង្គក្រាស់ក្រៃ ក៏ទ្រង់ត្រាស់បញ្ជាឱ្យអាមាត្យរត់ទៅតាម។ អាមាត្យរត់រឹងទៅ តាមទាន់ពេជ្ឈឃាតនៅទ្វារទិសឧត្តរក៏នាំមាយើងត្រឡប់មកវិញ។ ស្តេចព្រហ្មទត្តក៏ត្រាស់សួរមានយើងដឹងរឿងរ៉ាវសព្វគ្រប់អស់ហើយស្តេចព្រហ្មទត្តបានសុំទោសថៅមាយើងកុំឱ្យខឹងនឹងព្រះអង្គ ហើយក៏ប្រទានយសសក្តិដល់មាយើងយ៉ាងសមរម្យ។ មាយើងរស់នៅជាមួយភរិយាយ៉ាងសុខសាន្ត។

ថ្លៃពីនាយសំពៅកាលដែលបានដូរប្រពន្ធហើយ ហេតុតែនាងប្រពន្ធជាស្រីខាតលក្ខណ៍មិនជួយធ្វើការរកស៊ីអ្វីសោះគិតតែចាយ ពេលដែលកូនជុះអាចម៍ ជុះនោមនាងមិនយកទៅលាងទេតែងតែហែកព្រៃថ្មីៗជូតាហើយបោះចោលគ្មានស្តាយបន្តិចសោះ មាសប្រាក់ធ្លាប់មានក៏ត្រូវរលាយអស់ រហូតត្រូវលក់សំពៅចាយទៀត។

លុះអស់ប្រាក់ពីខ្លួនទាំងពីរនាក់ប្ដីប្រពន្ធកូនដើរសុំទានគេ។ ដើរសុំយូរៗទៅក៏ដល់ផ្ទះមាយើង នាងភរិយាមាយើងមិនដឹងក៏ហៅឱ្យទាន់ដូចសព្វដង ហើយក៏ស្គាល់ជាក់ជាអតីតស្វាមីនាងជានាយយសំពៅ ចុះឥឡូវម្ដេចក៏មកសុំទានគេវិញ។ ចំណែកនាយភេត្រាឃើញនាងអតីតភរិយាក៏ស្គាល់ហើយមានចិត្តអៀនខ្មាស់ក៏នាំប្រពន្ធកូនគេចបាត់ទៅ។

## ៣.១.២ ប្រធានរឿង

រឿងនេះនិយាយអំពីតម្លៃស្ត្រីនៅក្នុងគ្រួសារ។

## ៣.១.៣ មូលបញ្ហារឿង

- លក្ខណៈប្រពន្ធខាតលក្ខណ៍ និងប្រពន្ធគ្រប់លក្ខណ៍
- ការផ្លាស់ប្ដូរជីវភាពរស់នៅរបស់ចៅមាណព
- ការចូលខ្លួនទៅនៅក្នុងវាំងនៃចៅមាយើង
- ភាពរុងរឿងនៃគ្រួសារចៅមាយើង។

## ៣.១.៤ វិភាគតួអង្គ

- **ចៅមាណព(មាយើង)**

**+គុណសម្បត្តិ**

- ឧស្សាហ៍ព្យាយាមធ្វើការងារ
- មានកម្លាំងខ្លាំងក្លា
- ស្មោះត្រង់ចំពោះភរិយានិងព្រះមហាក្សត្រ
- បានប្រពន្ធល្អជាស្ត្រីគ្រប់លក្ខណ៍
- ជួយសង្គ្រោះជីវិតស្ដេច
- ក្លាយជាមន្ត្រីក្នុងវាំង។

**+គុណវិបត្តិ**

- មានតែកម្លាំងពុំសូវមានប្រាជ្ញា
- ថ្លើមធំហ៊ានយកអណ្ដាតលិទ្ធសុដនមហេសីស្ដេច។

- **នាយភេត្រា**

**+គុណសម្បត្តិ**

- ជាមហាសេដ្ឋីមានទ្រព្យច្រើន

**+គុណវិបត្តិ**

- គ្មានភក្ដីភាពចំពោះប្រពន្ធ
- ឈ្លក់វង្វេងនឹងសម្រស់ស្រី
- មិនចេះគិតគូរឱ្យបានវែងឆ្ងាយ។

○ **ប្រពន្ធទី១របស់មាយើង**

**+គុណសម្បត្តិ**

- មានសម្រស់ស្អាត

**+គុណវិបត្តិ**

- ជាស្រីកញ្ឆើឆ្កុះ
- ជាស្រីខាតលក្ខណ៍
- មិនចេះដែររក្សាទ្រព្យសម្បត្តិ
- មានចិត្តលោភលន់
- ខ្ជិលច្រអូល
- មិនចេះរាប់រកអ្នកជិតខាង។

○ **ប្រពន្ធទី២របស់មាយើង**

**+គុណសម្បត្តិ**

- ជាស្រីគ្រប់លក្ខណ៍
- ចេះយល់ការរាក់ជ្រៅ
- មានប្រាជ្ញាវាងវៃ
- ជាមេផ្ទះដ៏ល្អ

- ចេះរៀបចំទុកដាក់ទ្រព្យសម្បត្តិរកបាន
- ជួយឃើតយោងប្តីឱ្យមានបុណ្យសក្តិ។

+គុណវិបត្តិ

- យល់ព្រមដូរទៅធ្វើជាប្រពន្ធមាយើង ដោយមិនគិតថាខ្លួនជាស្រី

○ **ស្តេចព្រហ្មទត្ត**

+គុណសម្បត្តិ

- ជាស្តេចផែនដី
- មានព្រះទ័យសន្តោសចំពោះចៅមាយើង

+គុណវិបត្តិ

- មិនគោរពពាក្យសច្ចៈ
- គ្មានចេះគិតពិចារណាឱ្យបានវែងឆ្ងាយ
- មានចរិតឆេវឆាវ

## ៣.១.៥ វិភាគបញ្ហាផ្សេងៗ

❖ ចរិយាសាស្ត្រក្នុងសង្គមខ្មែរនាសម័យរឿងមាយើងៈ

តើក្នុងស័យនោះចរិយាសាស្ត្ររបស់មនុស្សមានសភាពបែបណាខ្លះ ?

តាមដំណើររឿងបានឆ្លុះបញ្ចាំងពីជីវភាពរស់នៅរបស់កសិករដែរ ធ្វើការប្រកបរបរចិញ្ចឹមជីវិតដោយការនេសាទត្រី(ជញ្ជាត់ត្រី) និងកាប់អុសសម្រាប់ចម្អិនអាហារ មានការលក់ដូរ ធ្វើជំនួញជាដើម ព្រមទាំងបង្ហាញពីការឱ្យតម្លៃរវាងប្តីប្រពន្ធ ក្នុងនោះផងដែរក៏បង្ហាញភាពអាត្មានិយមរបស់មនុស្សមួយចំនួនដែលពុំគិតវែងឆ្ងាយ គិតចង់ធ្វើអ្វីតាមតែចិត្ត មួយវិញទៀតឆ្លុះឱ្យឃើញរបបគ្រប់គ្រងនិងបង្ហាញពីពីចរិកនៃការដឹកនាំរបស់អ្នកដឹកនាំផងដែរ។ ហើយទិដ្ឋភាពទាំងនោះបានបង្ហាញតាមរយៈតួអង្គៈ

- មាណព(មាយើង) ជាតួអង្គបង្ហាញពីភាពតស៊ូក្នុងការប្រឹងប្រែងរកអាហារសម្រាប់ចិញ្ចឹមគ្រួសារ មានចិត្តស្រឡាញ់ប្រពន្ធ ដោយមិនចង់ឱ្យប្រពន្ធលំបាក មិនចេះថាស្តីឱ្យប្រពន្ធ(ប្រពន្ធទីមួយ) ចេះជួយអ្នកដទៃពីគ្រោះថ្នាក់(ស្តេចព្រហ្មទត្ត) មិនចេះប្រកែករកហេតុផលពេលដែលគេចាប់ខ្លួន មាណពជាមនុស្សចេះខំប្រឹងប្រែងតែជាមនុស្សដែលមិនសូវមានប្រាជ្ញនោះទេ រហូតពេលដែលនៅជាមួយប្រពន្ធទីពីរត្រូវបានប្រពន្ធណែនាំ ជារួមមាណពជាមនុស្សដែលមានកម្លាំងក្នុងការធ្វើការប្រៀប

បានទៅនឹងដៃជើងដែលចាំតែការបញ្ជាពីខួរក្បាល(នាងប្រពន្ធទីពីរ)។ នេះក៏សរឱ្យឃើញពីការគោរពឱ្យតម្លៃស្ត្រីជាប្រពន្ធនាសម័យនោះផងដែរ។

- នាយភេត្រា តាមសកម្មភាពបានបង្ហាញថាជាមនុស្សដែរចេះរកស៊ីជំនួញ តែជាមនុស្សដែរដែលមនុស្សស្មោះត្រង់ជាមួយប្រពន្ធរបស់ខ្លួន មើលមិនឃើញពីតម្លៃរបស់ប្រពន្ធខ្លួន និងមិនស្រឡាញ់ប្រពន្ធខ្លួនឃើញប្រពន្ធគេភ្លាម មានចិត្តចង់ក្បត់ប្រពន្ធខ្លួនឯង(ចោលជុំពេជ្រ ស្រវាជុំគ្រាស់)។
- នាងគ្រប់លក្ខណ៍ តាមរយៈសកម្មភាពរបស់នាងគឺបានលើកតម្លៃស្ត្រី ស្ត្រីបានជួយយោងបុរសដូចឃ្លាមួយពោលថា(ស្រណាបយោងដី ស្រីយោងប្រុស)។ ក្រោយពេលដែលមាណពរស់នៅជាមួយនាង មាណពបានលើកមុខមាត់ដោយសារតែនាងគ្រប់លក្ខណ៍បានប្រើគំនិតទំនុងបម្រុងគ្រប់បែបយ៉ាង លើសពីនោះនាងជាមនុស្សដែលឱ្យតម្លៃប្តីទោះដឹងថាប្តីមានប្រាជ្ញខ្សោយក៏ដោយ នាងតែងតែលើសរសើរប្តី និងនាំប្តីឱ្យអ្នកផងបានស្គាល់ រហូតនាងបាននាំប្តីឱ្យទៅនៅក្នុងវាំងរបស់ស្តេចថែមទៀត។ នាងគ្រប់លក្ខណ៍ចេះវិជ្ជាច្រើនយ៉ាងទាំងវិជ្ជាស្ត្រីមេផ្ទះ ការរកស៊ីជំនួញជាដើម។
- នាងខាតលក្ខណ៍ បានបង្ហាញពីចរិតរបស់ស្ត្រីដែរគិតតែពីធ្វើខ្លួន គិតថៃពីបំផ្លាញប្តីទាំងប្តីទីមួយនិងប្តីទីពីរ ដោយពុំគិតពីផលប្រយោជន៍ក្នុងគ្រួសារឡើយ ទាញទម្លាក់កិត្តិយសប្តីឱ្យមានភាពអាប់ឱន។
- ស្តេចព្រហ្មទត្ត ជាស្តេចដែលអាងអំណាច ចូលចិត្តការដើរព្រៃ ជាអ្នកដែរចូលចិត្តសប្បាយ(បំបោលសេះចោទគេ) ពុំគិតពិចារណាមុននឹងធ្វើអ្វីមួយ(បញ្ជាឱ្យគេយកមាយើងទៅសម្លាប់ដោយពុំរកហេតុផល)។

## ៣.២ វិភាគអត្ថរូប

### ៣.២.១ វិភាគពាក្យពេចន៍

អ្នកនិពន្ធប្រើជាពាក្យពេចន៍សាមញ្ញាធម្មតាងាយស្តាប ស្រួលយល់ ជាពាក្យខ្មែរសុទ្ធ សាយឡំនឹងពាក្យកម្ចីបាលីសំស្ក្រឹត ពាក្យកម្ចីសៀម និងពាក្យរាជសព្ទខ្លះៗ។

- **ពាក្យសាមញ្ញ៖** កាលនោះ ប្រសើរ ពេកពន់ ល្មមល្មៃ ពៀងលាង ហោង ចៅអើយ...។
- **ពាក្យកម្ចីបាលីសំស្ក្រឹត៖** ទុគ៌ត ភរិយា សោភា និត្យ មហិមា ភេត្រា ប្រពន្ធ...។
- **ពាក្យរាជសព្ទ៖** រាជទេពី ក្រសាល ទត ព្រះបាទ ព្រះក្រយា ព្រះឱស្ឋ សោយ...។
- **ពាក្យកម្ចីសៀម៖** គាប់ចៃ...។

### ៣.២.២ វិភាគជើងកាព្យ

នៅក្នុងរឿងមាយើងនេះឃើញថា អ្នកនិពន្ធបានប្រើវិធីតែងនិពន្ធដោយបទកំណាព្យ "បទកាកគិត បទភុជង្គលីលា បទពំនោល បទព្រហ្មគីត"។

## ៣.២.៣ រូបារម្មណ៍វិធី

### ក. ឧបមានរូបារម្មណ៍

| | | |
|---|---|---|
| ទើបគេគិតថ្វៃ | ថាចៅនេះនៃ | គាត់បានភរិយា |
| ទៀតទើបសប្បុរស | ពុំដូចសព្វគ្រា | នាងនេះលក្ខិណា |
| | មារយាទហ្មត់ហ្មង។ | |

### ខ. ចក្ខុរូបារម្មណ៍

| | | |
|---|---|---|
| ទ្រង់គ្រឿងរុងរឿងបញ្ចង់ | ព្រះពស្ត្រទិព្វទ្រង់ | ប៉ាក់ធ្លាក់មាលា។ |
| ...ក្លឹងក្លស់ខ្លង់ខ្លស់សោភា | ឆ័ត្ររតន៍ជយរចា | មរមាសរៀងអាយ។ |

### គ. ឃាន និងជីវ្ហារូបារម្មណ៍

| | | |
|---|---|---|
| ទឹកសោតពិសា | អប់អស់ក្លិនផ្កា | ពិដោរប្រពៃ |
| ស្តេចថានឹងចៅ | រសពិសាក្រៃ | ឱនាងគាប់ចៃ |
| | ចេះរៀបឱ្យប្តី។ | |

### ឃ. ចេតនារូបារម្មណ៍

| | | |
|---|---|---|
| មាយើងដាស់ស្តេច | ធាប់មួយរំពេច | ទើបទូលទៅថា |
| បពិត្រស្តេចឡើង | ដនៃអស្សា | ធាប់ៗម្ទឹម្នា |
| | ឥឡូវនេះនៃ។ | |
| ត្បិតមានទេវតា | និត្យនៅរក្សា | លើដើមព្រះជ្រៃ |
| ខឹងថាស្តេចនឹង | និយាយហើយនៃ | ផ្ទំលក់រឹកវៃ |
| | ស្មៀតមស្ងាត់សោភា។ | |

## ៣.៣ វិភាគអត្ថរស

### ៣.៣.១ តថរស

តម្លៃដែលអ្នកនិពន្ធលើកយកការពិតក្នុងសង្គមៈ

- ជីវភាពរសនៅរបស់ប្រជាជន(នេសាទ កាប់អុស ដួញដូរ...)
- លក្ខណៈអត្តរបស់មនុស្ស
- នយោបាយដឹងនាំប្រទេស(របបសក្តិភូមិ)

### ៣.៣.២ វីររស

បង្ហាញពីក្លាហានរបស់ថៅមាណពក្នុងការជួយសង្គ្រោះស្តេចព្រហ្មទត្តពីការសម្លាប់របស់ទេវតានៅគ្រប់កាលៈទេសៈ។

### ៣.៣.៣ សង្គមរស

លាតត្រដាងពីបញ្ហារបស់សង្គមដែលប្រកាន់យករបបផ្តាច់ការ កាត់ទោសមនុស្សតាមកំហឹងដោយគ្មានជំនុំជម្រះ និងលាតត្រដាងពីជីវភាពរស់នៅរបស់ប្រជាជនខ្មែរដែលប្រកបរបរធ្វើស្រែចម្ការ នេសាទត្រី និងដួញដូរជាលក្ខណៈគ្រួសារ។

### ៣.៣.៤ កុសលរស

- ចេះរៀបចំខ្លួនក្នុងនាមជាមេផ្ទះ
- ចេះរក្សាទ្រព្យសម្បត្តិ
- ត្រូវស្មោះត្រង់នឹងចៅហ្វាយនាយ
- ត្រូវចេះពិចារណាមុននឹងធ្វើអ្វីមួយ។

## IV ជំពូកទី៤៖ លក្ខណៈវិជ្ជមាន អវិជ្ជមាន (ឥទ្ធិពល តម្លៃសង្គម ការអប់រំ...)

### ៤.១ លក្ខណៈវិជ្ជមាន

នៅក្នុងរឿងមាយើងបានផ្តល់នូវលក្ខណៈវិជ្ជមានៈ

* បង្ហាញពីមនុស្សដែលមានប្រាជ្ញ តែងតែធ្វើអ្វីមួយទទួលបានជោគជ័យ ហើយជួយយឹតយោងអ្នកដែលនៅក្បែរខ្លួនទទួលបានតែរឿងល្អៗមកដាក់ខ្លួន។ ហើយរឿងនេះក៏បង្ហាញអប់រំទៅលើះ

- គ្រួសារៈ អប់រំឱ្យទំនាក់ទំនងរវាងប្តីប្រពន្ធឱ្យចេះគោរពស្រឡាញ់និងចេះឱ្យតម្លៃគ្នា ស្មោះត្រង់ចេះជួយផ្តល់ គំនិត អប់រំឱ្យប្រពន្ធចេះរក្សាទ្រព្យ ចេះវិជ្ជាមេផ្ទះ ព្រមទាំងអប់រំប្តីចេះគោរពប្រពន្ធនិងទទួលគំនិតល្អរបស់ ប្រពន្ធ...។

– សង្គមៈ ឥទ្ធិពលទៅលើការឱ្យតម្លៃស្ត្រី ដូចដែលនាងគ្រប់លក្ខណ៍ដែលជាស្ត្រីម្នាក់មានប្រាជ្ញាឆ្លាតវៃជាតឹកតាងស្រាប់។ ទន្ទឹមនឹងនោះ ក៏អប់រំទៅដល់អ្នកដឹកនាំមុននឹងសម្រេចចិត្តធ្វើអ្វីមួយត្រូវត្រិះរិះឱ្យបានល្អិតល្អន់។

## ៤.២ លក្ខណៈអវិជ្ជមាន

នៅក្នុងរឿងមាយើងបានផ្តល់នូវលក្ខណៈអវិជ្ជមានៈ

– ការដែលនាយភេត្រាជូរប្រពន្ធជាមួយមាណព បានផ្តល់នូវភាពមិនល្អនៅក្នុងសង្គមខ្មែរ

– ការដែលធ្វើអ្វីមួយដោយកំហឹង មិនបានពិចារណាធ្វើឱ្យមានភាពស្តាយក្រោយ(ព្រះបាទព្រហ្មទត្តនាយភេត្រា)។

# V ជំពូកទី៥៖ សន្និដ្ឋាន

រឿងមាយើងជារឿងអក្សរសិល្ប៍បែបសាស្ត្រល្បែងខ្មែរមួយដែលបានរួមចំណែកលើកស្ទួយតម្លៃស្ត្រីជាមនុស្ស សំខាន់នៅក្នុងគ្រួសារ។ រឿងនេះបានផ្តោតជាសំខាន់ទៅលើតួនាទីរបស់ស្ត្រីដែល ជាអ្នកជួយយឹតយោង និងបង្កលក្ខណៈឱ្យមានសុភមង្គលក្នុងសង្គមគ្រួសារក៏ដូចជាសង្គមជាតិ។ ដូចនេះស្ត្រីគ្រប់រូបត្រូវតែចេះរៀបចំ ឥរិយាបថ អត្តចរិត មារយាទឱ្យបានល្អប្រពៃក្នុងការទទួលយកនូវតួនាទី ដ៏ថ្លៃថ្លានេះ សមនឹងសុភាសិតខ្មែរចែង ថា "សំណាបយោងដីស្រីយោងប្រុស" ឬ "សម្លឆ្ងាញ់ដោយសារគ្រឿង គ្រួសាររុងរឿងត្បិតកិរិយាជា"។

ដូចនេះ រឿងមាយើងបានបង្ហាញពីចរិយាសាស្ត្រក្នុងសង្គមខ្មែរ ព្រមទាំងមានតម្លៃនៅក្នុងសង្គមខ្មែរជានិច្ច ស្របពេលនឹងបច្ចុប្បន្ន ដែលពិភពលោកកំពុងលើកម្ពស់តម្លៃសមភាពយេនឌ័រស្រាប់។

## ឯកសារពិគ្រោះ

ដកស្រង់ចេញពី*("រឿងមាយើង សម្រាប់ថ្នាក់ទី៦ ទំនើប នៃវិទ្យាល័យ-អនុវិទ្យាល័យ" បណ្ណាគារ **គឹម សេង** លេខ១២២ វិថីព្រះមុនីវង្ស ខេមរភូមិន្ទ ភ្នំពេញ និងសៀវភៅ "សិក្សាអត្ថបទអក្សរសិល្ប៍ខ្មែរ"រៀបរៀងដោយ **គង់ សុខហេង**)*។

ចប់